ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.........០០១/១៤.........គ.ម.ក/ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តនូវការកែប្រែ
# វិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## រដ្ឋមន្ត្រី
## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក/ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក/ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០២/១១ គ.ម.ក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៥/១១ គ.ម.ក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១ គ.ម.ក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ
- បានឃើញប្រកាសលេខ ០០១/១២ ស្ទួន២ គ.ម.ក/ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១២ ស្ទួន៣ គ.ម.ក/ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១២ ស្ទួន៤ គ.ម.ក/ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១៣ គ.ម.ក/ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំបន្ថបញ្ចុះថ្លៃសេវាប្រតិបត្តិការជួញដូរមូលបត្រ ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ និងថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា លើកទី២៧ នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ ២៤ថ្មី (ពីរ) នៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ២៤ថ្មី(មួយ) នៃវិធានប្រតិបត្តិការទីផ្សារ

មូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១៣ គ.ម.ក./ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ២.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៤ថ្មី(ពីរ) នៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៤ថ្មី(មួយ) នៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១៣ គ.ម.ក./ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

ដាក់ឱ្យអនុវត្តនូវប្រការ ១៣ថ្មី (ពីរ) នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ១៣ថ្មី(មួយ) នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១៣ គ.ម.ក./ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មករា ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ

  “ដើម្បីជូនជ្រាប”
- -ដូចប្រការ ៤

  “ដើម្បីអនុវត្ត”
- - រាជកិច្ច
- - ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..០០១....

ចុះថ្ងៃទី២២ខែ មករា ឆ្នាំ ២០១៤

ស្តីពី

## ការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

**ប្រការ ១៤ ថ្មី (ពីរ).- ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់ថ្លៃសេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)។

២-អ្នកបង់ថ្លៃសេវាគឺ ក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

៣-ពេលវេលានៃការបង់ថ្លៃសេវាគឺ នៅម៉ោង ៨: ៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

សម្រាប់ឆ្នាំ ២០១៤ ថ្លៃសេវាសម្រាប់ផាត់ទាត់និងទូទាត់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ ចំនុចទី ១ ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ)។